LONGBEACH COMMUNITY DEVELOPMENT

# សេចក្តីជូនដំណឹងសាធារណៈ

## សេចក្តីជូនដំណឹងអំពីសវនាការសាធារណៈ និងឯកសារដែលមានជូនសាធារណជន

នៅថ្ងៃ ពុធ ទី **០៥ ខែ មិថុនា ឆ្នាំ ២០២៤** វេលាម៉ោង ៤ ល្ងាច ក្រុមហ៊ុនវិនិយោគសហគមន៍ក្រុងឡុងប៊ិច នឹងរៀបចំសវនាការសាធារណៈមួយ នៅសាលាក្រុងឡុងប៊ិច នៅទីតាំងអគារលេខ 411 W. Ocean Blvd. បន្ទប់ប្រជុំជាន់ទីពីរ Long Beach, CA 90802។

សវនាការនេះមានគោបំណង ផ្តល់ឱកាសឲ្យសាធារណជនបញ្ចេញមតិ អំពីផែនការសកម្មភាពឆ្នាំសារពើពន្ធ ២០២៤-២០២៥ (ផែនការ) ដែលដោះស្រាយចំណុចអាទិភាពក្នុងផែនការរួមបច្ចុប្បន្ននេះ។ ជារៀងរាល់ឆ្នាំ សាលាក្រុងឡុងប៊ិចទទួលបានប្រាក់ពីនាយកដ្ឋានលំនៅឋាន និងអភិវឌ្ឍន៍ទីក្រុងនៃសហរដ្ឋអាមេរិក ដើម្បីជួយកែលម្អភូមិរបស់យើង។ មូលនិធិទាំងនេះបានពីប្រភពបី៖ ថវិកាជំនួយសម្រាប់គម្រោងអភិវឌ្ឍន៍សហគមន៍ ថវិកាជំនួយដំណោះស្រាយគ្រាអាសន្ន និងច្បាប់ស្តីពីភាពជាដៃគូវិនិយោគលំនៅឋាន។

ចាប់ផ្តើមពីថ្ងៃទី **០៣ ខែ ឧសភា ឆ្នាំ ២០២៤** ឯកសារព្រាងនៃផែនការសកម្មភាពឆ្នាំសារពើពន្ធ ២០២៤-២០២៥ នឹងមានសម្រាប់សាធារណជនពិនិត្យ និងផ្តល់គំនិត។ កម្រិតនៃមូលនិធិដែលបង្ហាញក្នុងផែនការព្រាងនោះ គឺជាចំនួនប៉ាន់ស្មាន និងអាចប្រែប្រួលទៅតាមចំនួនជាក់ស្តែងចុងក្រោយ។ ផែនការព្រាងនេះនឹងមានដាក់ឲ្យទាញយកពីផ្នែកនេះ៖ “Stay Informed: Latest News” នៃគេហទំព័ររបស់នាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ក្រុងឡុងប៊ិច longbeach.gov/lbcd, មកយកដោយផ្ទាល់នៅអគារលេខ 411 W. Ocean Blvd., Long Beach, CA 90802 ឬ ដោយទាក់ទងអ្នកស្រី Elizabeth Weithers តាមអ៊ីម៉េល Elizabeth.Weithers@longbeach.gov ឬតាមទូរស័ព្ទ៖ (562) 570-6912។

សាលាក្រុងឡុងប៊ិចមានបំណងផ្តល់ការសម្របសម្រួលសមស្រប សម្រាប់ការចូលរួមសវនាការសាធារណៈនេះ ដោយគោរពតាមច្បាប់ស្តីពីជនពិការអាមេរិក (ADA) ឆ្នាំ ១៩៩០។ បើបងប្អូនត្រូវការឲ្យជួយសម្រួលសម្រាប់ជនពិការ ឬស្នើសុំសំណេរបកប្រែឯកសារនេះ សូមទូរស័ព្ទទៅអ្នកស្រី Elizabeth Weithers តាមលេខ (562) 570-6912 ឲ្យបានយ៉ាងហោចណាស់ ៤៨ ម៉ោង នៅមុនថ្ងៃរៀបចំសវនាការសាធារណៈ នៅថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ ២០២៤ នោះ។ បងប្អូនប្រជាពលរដ្ឋដែលមានបំណងផ្តល់មតិជាលាយលក្ខណ៍អក្សរ ត្រូវធ្វើឲ្យបានត្រឹមថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០២៤។ សម្រាប់បងប្អូនដែលថ្លង់ ឬគ សូមទូរស័ព្ទទៅលេខ 711 ដើម្បីភ្ជាប់ទៅនឹងសេវាទំនាក់ទំនង មតិជាលាយលក្ខណ៍អក្សរ អាចផ្ញើទៅអ្នកស្រី Elizabeth Weithers នៃនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍អគារលេខ 411 W. Ocean Blvd., Long Beach, CA 90802 ឬផ្ញើតាមអ៊ីម៉េលទៅ Elizabeth.Weithers@longbeach.gov។

បើបងប្អូនមានបំណងស្នើសុំឯកសារនេះជាទម្រង់ផ្សេងពីនេះ ឬស្នើសុំឲ្យមានការជួយសម្រួលដល់ជនពិការ សូមទាក់ទងទៅនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ តាម longbeach.gov/lbcd ទូរស័ព្ទលេខ៖ 562.570.3807។ យើងខ្ញុំត្រូវការរយៈពេលបីថ្ងៃនៃថ្ងៃធ្វើការ ដើម្បីធានាឆ្លើយតបទៅតាមសំណូមពរ។ ទោះជាយ៉ាងនេះក្តី យើងខ្ញុំនឹងព្យាយាមដោះស្រាយជូនតាមសំណូមពរ បើទោះបីជាសំណើនោះដាក់កៀកថ្ងៃជាងនេះក៏ដោយ។